អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១២ ចេញផ្សាយ ខែធ្នូ ឆ្នាំ២០២២

## ការវាយតម្លៃហានិភ័យ




### និយមន័យ

ហានិភ័យ គឺជាព្រឹត្តការណ៍ដែលអាចកើតឡើង ហើយជះឥទ្ធិពលអវិជ្ជមានដល់ការសម្រេចនូវភារកិច្ច គោលបំណង និងការអនុវត្តយុទ្ធសាស្ត្ររបស់ស្ថាប័ន។

ការវាយតម្លៃហានិភ័យតាមរយៈនីតិវិធីសវនកម្ម គឺជាមូលដ្ឋានមួយសម្រាប់រៀបចំផែនការសវនកម្ម ឬកម្មវិធីសវនកម្មដែលនឹងជួយដល់ការអនុវត្តកិច្ចដំណើរការសវនកម្ម ក៏ដូចជាកាត់បន្ថយនូវការមើលរំលងនូវបញ្ហាសំខាន់ៗឱ្យនៅកម្រិតទាប និងបែងចែកធនធានសវនកម្មចំពោះបញ្ហាដែលមិនសូវសំខាន់។

### គោលបំណងនៃការវាយតម្លៃហានិភ័យ




គោលបំណងនៃការវាយតម្លៃហានិភ័យគឺដើម្បី៖

១. កំណត់អត្តសញ្ញាណ និងវាយតម្លៃផលប៉ះពាល់នៃហានិភ័យដែលអាចគំរាមកំហែងលើគោលបំណងរបស់សវនដ្ឋាន។

២. បង្កើតសវនកម្មសក្តានុពល និងផែនការសវនកម្ម។

ជារួម គោលបំណងសំខាន់នៃការវាយតម្លៃហានិភ័យ គឺដើម្បីកំណត់អំពីបញ្ហានានា ដែលមានហានិភ័យខ្ពស់ សម្រាប់ផ្តោតការយកចិត្តទុកដាក់លើការធ្វើសវនកម្ម ក្នុងគោលបំណងបង្កើនឱ្យបានជាអតិបរមានូវគុណតម្លៃការងារសវនកម្មផ្ទៃក្នុងលើកិច្ចប្រតិបត្តិការនានាក៏ដូចជាការកាត់បន្ថយហានិភ័យសវនកម្មឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមា។

### មូលដ្ឋាននៃការវាយតម្លៃហានិភ័យ




សវនករត្រូវកំណត់ដោយឯករាជ្យនូវហានិភ័យដែលជាគោលដៅនៃការធ្វើសវនកម្ម ដោយផ្អែកលើទិន្នន័យ និងព័ត៌មានដែលប្រមូលបាននៅក្នុងដំណាក់កាលចុះស្វែងយល់សវនដ្ឋាន។

ការវាយតម្លៃហានិភ័យត្រូវផ្អែកលើភាពដែលអាចកើតមានឡើង និងមានផលប៉ះពាល់ដល់ប្រតិបត្តិការរបស់សវនដ្ឋាន។ អាស្រ័យហេតុនេះ ហានិភ័យទាំងនោះត្រូវធ្វើការកំណត់ និងវាស់វែងឱ្យបានច្បាស់លាស់ពីផលប៉ះពាល់ក្នុងអំឡុងពេលនៃការវាយតម្លៃហានិភ័យ។


ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១២ ចេញផ្សាយ ខែធ្នូ ឆ្នាំ២០២២

សវនករត្រូវពិចារណាលើសមាសធាតុចំនួន ៣ (បី) នៃហានិភ័យ ដែលពាក់ព័ន្ធនឹងប្រធានបទសវនកម្មដូចខាងក្រោម៖

**១. ហានិភ័យដែលមានស្រាប់**

**២. ហានិភ័យត្រួតពិនិត្យ**

**៣. ហានិភ័យតាមរក/តាមចាប់**

លទ្ធផលហានិភ័យទាំង ៣ ប្រភេទនេះ បង្ហាញពីហានិភ័យសវនកម្ម។ រូបមន្តសម្រាប់ធ្វើការវាយតម្លៃហានិភ័យសវនកម្មមានដូចខាងក្រោម៖

| |
|---|
| **ហានិភ័យសវនកម្ម =** ហានិភ័យដែលមានស្រាប់ x ហានិភ័យត្រួតពិនិត្យ x ហានិភ័យតាមរក/តាមចាប់។ |




ហានិភ័យនីមួយៗ គឺត្រូវវាយតម្លៃដោយផ្អែកលើភាពជាសារវ័ន្ត និងភាពញឹកញាប់ដែលអាចកើតឡើងនៅក្នុងស្ថានភាពកំពុងមាន ដោយប្រើវង្វាស់មួយបង្កើតដោយក្រុមការងារសវនកម្ម។ ***ឧទាហរណ៍៖ ខ្ពស់ មធ្យម ឬទាប។***

## គុណភាពនៃការវាយតម្លៃហានិភ័យ

វិធីសាស្ត្រចំនួន ៣(បី) ដែលអាចជួយលើកកម្ពស់គុណភាពនៃការវាយតម្លៃហានិភ័យ៖

- **ការពិភាក្សាជាមួយថ្នាក់ដឹកនាំ៖** សវនករត្រូវពិភាក្សាជាមួយថ្នាក់ដឹកនាំអំពី គោលបំណងការរំពឹងទុក និងផែនការសវនកម្ម។
- **ការវិភាគ៖** អាចជួយសវនករក្នុងការកំណត់កិច្ចប្រតិបត្តិការមិនប្រក្រតី ឬអសកម្ម និងជួយក្នុងការវាយតម្លៃហានិភ័យ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការឆ្លើយតបទៅនឹងហានិភ័យដែលបានកំណត់។
- **ការសង្កេត៖** នីតិវិធីនៃការសង្កេតអាចផ្តល់ឱ្យសវនករនូវព័ត៌មានក្នុងការស្វែងយល់ និងការវាយតម្លៃបរិស្ថានរបស់សវនដ្ឋាន។

**អត្ថបទ៖ កញ្ញា នួន គន្ធារស្មី**

**ឯកសារយោង៖**

១. គោលការណ៍ណែនាំស្តីពីសវនកម្មអនុលោមភាពរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**

២. សៀវភៅ ណែនាំសវនកម្មផ្ទៃក្នុង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣. សៀវភៅ ណែនាំសវនកម្មផ្ទៃក្នុង របស់គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) របស់ក្រសួងមហាផ្ទៃ។